# ព្រះវជ្រសត្វនៅក្នុងសិល្បៈខ្មែរ

ព្រះពុទ្ធសាសនាមហាយានជាសាសនាមួយដែលគោរពព្រះពុទ្ធច្រើនព្រះអង្គនិងច្រើនក្រុម ហើយសាសនានេះក៏បានបែកខ្នែងជានិកាយតូចៗជាច្រើននិកាយផងដែរ។ ជាទូទៅគេចែកព្រះពុទ្ធក្នុងពុទ្ធសាសនាមហាយានជា៣ក្រុម រៀងកម្រិតគ្នាតាមលំដាប់ដោយព្រះពុទ្ធដែលមានកម្រិតខ្ពស់ជាគេគឺ ព្រះអាទិពុទ្ធ(Ādi-Buddha) (កម្រិត១) ទ្រង់បានបង្កើតព្រះពុទ្ធមួយក្រុមទៀតគឺព្រះធ្យានិពុទ្ធ(Dhyāni Buddha) ដែលជាទូទៅមាន៥ព្រះអង្គ (កម្រិត២) សម្រាប់មើលថែរក្សាលោក។ ព្រះធ្យានិពុទ្ធត្រូវវេនគ្នាដើម្បីថែរក្សាលោកតាមកប្បនីមួយៗ ទ្រង់មានកាយទិព្វប្រថាប់នៅលើឋានសួគ៌ ហើយទ្រង់មិនចុះមកប្រោសសត្វលោកនៅឋានមនុស្សដោយផ្ទាល់ទេ។ ដូចនេះទ្រង់បានបង្កើតមនុសិពុទ្ធ (Manushi Buddha) (កម្រិត៣) ឱ្យមកកើតនៅឋានមនុស្សដើម្បីប្រោសសត្វលោកដោយផ្ទាល់។ ព្រះពុទ្ធក្រុមនេះមិនមានកាយទិព្វអមតនោះទេ តែចេះកើតចាស់ឈឺស្លាប់ដូចមនុស្សធម្មតា។ ដោយហេតុថាមនុសិពុទ្ធមិនអាចនៅជាអមតបាន ដូចនេះព្រះធ្យានិពុទ្ធបានបង្កើតឱ្យមានព្រះធ្យានិពោធិសត្វដើម្បីចុះមកមើលថែរក្សាសត្វលោកអំឡុងពេលដែលព្រះមនុសិពុទ្ធចូលបរិនិព្វាន និងរង់ចាំមនុសិពុទ្ធអង្គថ្មីមកកើត។[១]

ជាឧទាហរណ៍ នៅក្នុងកប្បបច្ចុប្បន្ននេះ ព្រះធ្យានិពុទ្ធព្រះនាម អមិតាភៈ ជាអ្នកមើលថែរក្សាលោក ទ្រង់ប្រថាប់នៅឋានសួគ៌ឈ្មោះ សុខាវតី។ ទ្រង់បានបង្កើតឱ្យមានព្រះមនុសិពុទ្ធព្រះនាមសក្យមុនីដើម្បីឱ្យចុះមកប្រោសត្វដោយផ្ទាល់។ ក្រោយពីព្រះមនុសិពុទ្ធចូលបរិនិព្វានទៅ ព្រះអមិតាភៈបានចាត់ឱ្យព្រះពោធិសត្វព្រះនាមអវលោកិតេស្វរចុះមកមើលថែរក្សាសត្វលោកអំឡុងពេលដែលលោកនេះមិនមានមនុសិពុទ្ធ។ ហេតុនេះហើយទើបព្រះពោធិសត្វអវលោកិតេស្វរមានការគោរពយ៉ាងខ្លាំងនៅក្នុងចំណោមអ្នកកាន់ពុទ្ធសាសនាមហាយាន។

ចំពោះព្រះវជ្រសត្វវិញ ទ្រង់ជាព្រះសំខាន់មួយអង្គក្នុងចំណោមព្រះជាច្រើនអង្គដែលគេគោរពនៅក្នុងពុទ្ធសាសនាមហាយានដែរ។ តែឋានៈរបស់ទ្រង់មានភាពមិន

[១] ចេមរ៉ូ តិចស័ញ្ជលី 2015, 35-37.

អត្ថបទដោយៈ ឡេង ស៊ីវ៉េង

ច្បាស់លាស់នោះទេ ដោយមានការប្រែប្រួលអាស្រ័យទៅតាមការនិយមគោរពតាមនិកាយនិងនៅតាមតំបន់នីមួយៗ។ ជាក់ស្តែងអ្នកគោរពពុទ្ធសាសនាបែបវជ្រយាននៅប្រទេសនេប៉ាល់បានចាត់ទុកទ្រង់ជាព្រះធ្យានិពុទ្ធអង្គទី៦ ទ្រង់មិនប្រចាំនៅទិសណាមួយដូចធ្យានិពុទ្ធ៥អង្គផ្សេងទៀតទេ ហើយការបូជាទ្រង់ទៀតសោតក៏ធ្វើនៅកន្លែងសម្ងាត់និងមិនបើកចំហចំពោះអ្នកមិនចូលវជ្រយានឡើយ[២]។ ដោយឡែកពុទ្ធសាសនាមហាយាននិកាយស្វាភាវិក (Svābhāvika) បានលើកព្រះវជ្រសត្វឱ្យមានឋានៈជាព្រះអាធិពុទ្ធទៀតផង។ ហើយពេលខ្លះព្រះអង្គក៏មានឋានៈជាព្រះពោធិសត្វដែលនៅក្រោមឱវាទនៃព្រះធ្យានិពុទ្ធនាមអក្សោភ្យ (Akṣobhya)ផងដែរ[៣]។

នៅក្នុងគម្ពីរអទ្វយវជ្រសំគ្រហ(Advayavajra Saṁgraha)បានរៀបរាប់ពីលក្ខណៈនៃព្រះវជ្រសត្វថាគឺ ទ្រង់មានសម្បុរស មានព្រះសិរមួយ មានព្រះហស្ត២ នៅព្រះហស្តស្តាំកាន់វជ្រ លើកឡើងត្រឹមព្រះឧរា(ទ្រូង) ព្រះហស្តឆ្វេងកាន់កណ្តឹងដាក់លើព្រះឩរូ(ភ្លៅ)។[៤] ក្រៅពីនេះព្រះអង្គច្រើនទ្រង់ភ្នែននៅលើបល្ល័ង្កផ្កាឈូក ហើយទ្រង់មិនគ្រងចីពរបែបព្រះសង្ឃដូចព្រះធ្យានិពុទ្ធដទៃទេ តែព្រះអង្គទ្រង់គ្រឿងបែបក្សត្រដូចព្រះពោធិសត្វទៅវិញ (**រូបភាពទី១**)។ ក្នុងករណីព្រះវជ្រសត្វជាព្រះពោធិសត្វនឹងមានការធ្វើរូបព្រះធ្យានិពុទ្ធអក្សោភ្យប្រដាប់នៅលើមកុដ ។

[២] B. Bhattacharyya 1958, 74-75.

[៣] ผาสุข อินทราวุธ 2000, 61.

[៤] B. Bhattacharyya 1958, 75.

អត្ថបទដោយៈ ឡេង ស៊ីវ៉ង់

អរិយធម៌ខ្មែរ KHMER CIVILIZATION



រូបភាពទី១៖ ព្រះវជ្រសត្វក្នុងសិល្បៈបាលៈ បច្ចុប្បន្ននៅ Indian Museum (រូបថត៖ Biswarup Ganguly)

ដោយឡែកសម្រាប់សង្គមខ្មែរវិញទំនងជាបានស្គាល់ព្រះវជ្រសត្វយ៉ាងហោចណាស់តាំងពីសតវត្សរ៍ទី១១ មកម្ល៉េះ។ គេប្រទះឃើញព្រះនាមរបស់ទ្រង់មានលើកឡើងនៅក្នុងសិលាចារឹកសប្បាក ចុះលេខសម្គាល់ K.១១៥៨ សរសេរជាភាសាសំស្ក្រឹតនិងខ្មែរបុរាណ ចារឡើងនៅឆ្នាំ១០៦៦ ក្នុងរជ្ជកាលព្រះបាទឧទ័យាទិត្យវម៌្មទី២ (**រូបភាពទី**២)។ នៅក្នុងសិលាចារឹកដែលជាផ្នែកសំស្ក្រឹតត្រង់ស្លោកទី១និងទី២ បានសរសេរនមស្ការថ្វាយបង្គំចំពោះព្រះពុទ្ធទាំង៥ព្រះអង្គ (ធ្យានិពុទ្ធ) និងលំដាប់ទី៦នមស្ការថ្វាយបង្គំចំពោះព្រះវជ្រសត្វ។ ការនមស្ការព្រះវជ្រសត្វនៅដំដាប់ទី៦នេះ ហាក់បង្ហាញថាទ្រង់មានកម្រិតស្មើនឹងព្រះធ្យានិពុទ្ធទាំង៥ព្រះអង្គមុន ហេតុនេះហើយទើបមានការយល់ឃើញថាព្រះវជ្រសត្វនៅក្នុងសិលាចារឹកនេះទំនងមានឋានៈជាព្រះធ្យានិយពុទ្ធអង្គទី៦[៥]។

---

[៥] Chirapat Prapandvidya 1990, 11-14. Songtham Pansakun 2005, 136-142. សួន សុកគ្រា ២០១៨, ២-១៦។

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

តាមរយៈព័ត៌មាននេះធ្វើឱ្យយើងដឹងថា សង្គមខ្មែរសម័យអង្គរទំនងជាបានលើកព្រះវជ្រសត្វឱ្យមានឋានៈជាព្រះធ្យានិពុទ្ធអង្គទី៦ដូចនៅក្នុងប្រទេសនេប៉ាល់ដែរ។



*រូបភាពទី២៖ សំណៅសិលាចារឹកសប្បាក (សំណៅ៖ ฐานข้อมูลจารึกแห่งประเทศไทย)*

ចំពោះការសាងបតិមាព្រះវជ្រសត្វនៅក្នុងសិល្បៈខ្មែរយ៉ាងហោចណាស់ចាប់ផ្តើមលេចឡើងនៅរវាងសតវត្សរ៍ទី១២។ ជាស្តែងចម្លាក់ព្រះវជ្រសត្វធ្វើពីសំរឹទ្ធមួយចំនួនដែលដាក់តាំងនៅក្នុងសារមន្ទីរជាតិភ្នំពេញ និងព្រះវជ្រសត្វធ្វើអំពីសំរឹទ្ធមួយចំនួនដែលដាក់តាំងនៅសារមន្ទីរជាតិបាងកក ប្រទេសថៃជាដើម។ លក្ខណៈទូទៅ ខាងបដិមាសាស្ត្រនៃបដិមារទាំងនោះមានទម្រង់ដូចគ្នាទៅនឹងសិល្បៈឥណ្ឌាដែរ ដូចជាទ្រង់មានព្រះសិរមួយ ព្រះហស្ត២ ព្រះហស្តខាងស្តាំកាន់វជ្រលើកខ្ពស់ត្រឹមព្រះឱរា ព្រះហស្តឆ្វេងកាន់កណ្តឹងដាក់លើព្រះឧរូ ចំណែកឥរិយាបថប្រថាប់គង់វិញ ទ្រង់ភ្នែនលើបល្ល័ង្កផ្កាឈូក (**រូបភាពទី៣-៤**)។ តែអ្វីដែលគួរឱ្យកត់សម្គាល់គឺ ចម្លាក់ព្រះវជ្រសត្វដែលគេរកឃើញកន្លងមកច្រើនជាបដិមាសំរឹទ្ធតូចៗ មិនធំដូចបដិមានដទៃឡើយ។ ការនិយមធ្វើបដិមាមាទំហំតូចបែបនេះទំទងជាបណ្តាលមកពីរបៀបនៃការគោរពបូជាព្រះវជ្រសត្វត្រូវធ្វើនៅកន្លែងសម្ងាត់និង

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

មិនបើកចំហចំពោះមនុស្សទូទៅ ដូចនេះការធ្វើរូបតូចៗគឺងាយស្រួលទុកដាក់ និងស្រួលលាក់កំបាំងពីភ្នែកមនុស្សទូទៅ។



រូបភាពទី៣៖ ព្រះវជ្រសត្វក្នុងសិល្បៈខ្មែរ បច្ចុប្បន្ននៅសារមន្ទីរជាតិភ្នំពេញ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបភាពទី៤៖ ព្រះវជ្រសត្វក្នុងសិល្បៈខ្មែរ បច្ចុប្បន្ននៅសារមន្ទីរជាតិបាងកក (រូបថត៖ ឡេង ស៊ីវ៉ង់)

វត្តមានរបស់ព្រះវជ្រសត្វនៅក្នុងសិល្បៈខ្មែរបានក្លាយជាផ្នែកមួយនៃការឆ្លុះបញ្ចាំងឱ្យឃើញអំពីឥទ្ធិពលរបស់ពុទ្ធសាសនាមហាយាននិកាយវជ្រយាននៅក្នុងសង្គមខ្មែរបានយ៉ាងល្អ។ តាមរយៈភស្តុតាងពីសិលាចារឹកនិងបដិមារូបគោរពខាងលើធ្វើគេដឹងថា ព្រះពុទ្ធសាសនាមហាយាននិកាយវជ្រយានទំនងជាចាប់ផ្តើមមានវត្តមានយ៉ាងច្បាស់នៅក្នុងសង្គមខ្មែរយ៉ាងហោចណាស់នៅរវាងសតវត្សរ៍ទី១១។

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

# បញ្ជីឯកសារយោង

សួន សុកគ្រា.

២០១៨, "ប្រពុទ្ធសាសនានៅប្រទេសកម្ពុជាសម័យបុរាណ" ក្នុង កម្រងអត្ថបទស្រាវជ្រាវវប្បធម៌ខ្មែរ. លេខ២, ទំ. ២-១៦។

B. Bhattacharyya

1958, The Indian Buddhist Iconography: Mainly Based on the Sādhanamālā and Cognate Tāntric Texts of Rituals, 2nd edition, A.C. Ghosh, Calcutta.

Chirapat Prapandvidya.

1990, "The Sab Bak Inscription: Evidence of an Early Vajrayana Buddhism Presence in Thailand", In The Journal of the Siam Society 79.2, 11-14.

Songtham Pansakun.

2005, Buddhism Traces in Ancient Khmer Empire Before 12 A.D., Master Degree Thesis, Department of Oriental Languages, Silpakorn University.

ผาสุข อินทราวุธ

2000, พุทธปฏิมาฝ่ายมหายาน, อักษรสมัย, กรุงเทพฯ.

เชษฐ์ ติงสัญชลี.

2015, ประวัติศาสตร์ศิลปะอินเดียและเอเชียตะวันออกเฉียงใต้, มิวเซียมเพรส, นนทบุรี.